HELEN KELLER INTL | ARCH ASSESSMENT & RESEARCH ON CHILD FEEDING

# បទពិសោធន៍ស្តីពីការអនុវត្តសាកល្បងប្រព័ន្ធតាមដានត្រួតពិនិត្យការអនុវត្តក្រមអន្តរជាតិស្តីពីការផ្សព្វផ្សាយលក់ផលិតផលជំនួសទឹកដោះម្តាយក្នុងប្រទេសកម្ពុជា

សូមទាញយកអត្ថបទពីគេហទំព័រ: https://onlinelibrary.wiley.com/doi/full/10.1111/mcn.12795

សេចក្តីសង្ខេប

ការតាមដានត្រួតពិនិត្យនិងការពង្រឹងការអនុវត្តក្រមអន្តរជាតិស្តីពីការផ្សព្វផ្សាយលក់ផលិតផលជំនួសទឹកដោះម្តាយរបស់អង្គការសុខភាពពិភពលោកនៅទូទាំងពិភពលោក នៅពុំទាន់មានយន្តការអនុវត្តជាក់លាក់នៅឡើយ ។ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តក្រមអន្តរជាតិនេះដោយបង្កើតឱ្យមានស្តង់ដារអនុវត្តជាតិ ដែលអាចអនុវត្តក្រមអន្តរជាតិនេះបាន តាមរយៈការបង្កើតនូវអនុក្រឹត្យលេខ១៣៣ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ការចិញ្ចឹមទារកនិងកុមារ ។ ក្រោយពីមានការបង្កើតក្រុមប្រឹក្សាតាមដានការអនុវត្តអនុក្រឹត្យលេខ១៣៣និងគោលការណ៍ណែនាំលម្អិតស្តីពីការអនុវត្តត្រួតពិនិត្យនិងពង្រឹងអនុក្រឹត្យលេខ១៣៣ ការអនុវត្តក្នុងដំណាក់កាលសាកល្បងរយៈពេល៧ខែត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៧ក្នុងគោលបំណងដើម្បីធ្វើតេស្តប្រព័ន្ធតាមដានត្រួតពិនិត្យអនុវត្តអនុក្រឹត្យ១៣៣ក្នុងបណ្តាខេត្តសាកល្បងចំនួន៤។

ក្នុងដំណាក់កាលនៃការសាកល្បងនេះសកម្មភាពសំខាន់ៗត្រូវបានធ្វើឡើងរួមមានការបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យនៃក្រសួងសុខាភិបាលនិងក្រសួងពាណិជ្ជកម្ម ដោយមានការចុះតាមដានត្រួតពិនិត្យរកមើលករណីរំលោភបំពានអនុក្រឹត្យលេខ១៣៣នៅតាមបណ្តាទីតាំងលក់និងមូលដ្ឋានសុខាភិបាល ការធ្វើតេស្តយន្តការរាយការណ៍ការរំលោភបំពាននិងវិធានការណ៍ដោះស្រាយលើករណីរំលោភបំពានផងដែរ ។ ក្នុងដំណាក់កាលសាកល្បងនេះមន្ត្រីត្រួតពិនិត្យថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិចំនួន៨៥រូបបានទទួលការបណ្តុះបណ្តាលការអនុវត្តអនុក្រឹត្យលេខ១៣៣ ក្នុងនោះមានការចុះត្រួតពិនិត្យចំនួន៣៩២កន្លែង តារាងនិងបញ្ជីវិនិច្ឆ័យត្រួតពិនិត្យចំនួន២៣៧៧ត្រូវបានបំពេញ ព្រមទាំងបានចេញលិខិតព្រមានផ្លូវការចំនួន១១ទៅក្រុមហ៊ុនដែលរំលោភបំពានអនុក្រឹត្យលេខ១៣៣ផងដែរ។ បើទោះបីជាមន្ត្រីត្រួតពិនិត្យ ពុំទាន់បានផ្ញើរបាយការណ៍រំលោភបំពានទៅកាន់ក្រុមការងារប្រតិបត្តិអនុក្រឹត្យលេខ១៣៣ក៏ដោយ យោងតាមការពិនិត្យទិន្នន័យក្នុងតារាងនិងបញ្ជីវិនិច្ឆ័យត្រួតពិនិត្យបានរកឃើញថាមានចំនួនពាក់កណ្តាល ឬ៥២,៩% មានការរំលោភបំពានអនុក្រឹត្យលេខ១៣៣។

ការពង្រឹងការអនុវត្តអនុក្រឹត្យលេខ១៣៣នៅក្នុងដំណាក់កាលសាកល្បងនេះបានបង្ហាញថា សកម្មភាពសំខាន់ៗមួយចំនួននៃប្រព័ន្ធតាមដានត្រួតពិនិត្យអនុក្រឹត្យលេខ១៣៣ គួរតែត្រូវបានកែសម្រួលរួមមាន: ការដាក់បញ្ចូលការបណ្តុះបណ្តាលខ្លឹមសារនៃការអនុវត្តអនុក្រឹត្យលេខ១៣៣ទៅក្នុងផែនការនិងកម្មវិធីបណ្តុះបណ្តាលរបស់ក្រសួងពាក់ព័ន្ធនីមួយៗដើម្បីធានានិរន្តភាព កំណត់លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសិក្ខាកាមគោលដៅដែលជាមន្ត្រីត្រួតពិនិត្យចូលរៀនវគ្គបណ្តុះបណ្តាល កំណត់ច្បាស់លាស់ពីការបែងចែកតួនាទីភារកិច្ច និងការទទួលខុសត្រូវការងាររវាងមន្ត្រីត្រួតពិនិត្យថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ កែសម្រួលទម្រង់នៃតារាងនិងបញ្ជីវិនិច្ឆ័យត្រួតពិនិត្យនិងទម្រង់រាយការណ៍ករណីរំលោភបំពានឱ្យកាន់តែសាមញ្ញព្រមទាំងមានភាពងាយស្រួលជាងមុន  ធ្វើឱ្យកាន់តែប្រសើរឡើងនូវការដាក់បញ្ចូលសកម្មភាពត្រួតពិនិត្យអនុក្រឹត្យលេខ១៣៣ទៅក្នុងផែនការសកម្មភាពត្រួតពិនិត្យជារួមរបស់ក្រសួងនីមួយៗដែលកំពុងអនុវត្តន៍ស្រាប់។

ដូច្នេះដើម្បីឱ្យប្រព័ន្ធតាមដានត្រួតពិនិត្យនិងអនុវត្តអនុក្រឹត្យលេខ១៣៣អាចនឹងអនុវត្តបានដោយជោគជ័យទៅកាន់បណ្តាខេត្តទាំងអស់ក្នុងប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើការកែសម្រួលទៅលើសកម្មភាពសំខាន់ៗខាងលើជាមុនសិន។បញ្ហាប្រឈមនិងបទពិសោធន៍នៃការអនុវត្តក្រមអន្តរជាតិនៅក្នុងប្រទេសកម្ពុជាអាចត្រូវបានប្រើប្រាស់ជាឯកសារណែនាំក្នុងការចែករំលែកមេរៀនពិសោធន៍នានាដល់បណ្តាប្រទេសផ្សេងៗដែលកំពុងប្រឹងប្រែងអនុវត្តការតាមដានត្រួតពិនិត្យការអនុវត្តក្រមអន្តរជាតិស្តីពីការផ្សព្វផ្សាយលក់ផលិតផលជំនួសទឹកដោះម្តាយ។